ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈស្ថាបត្យករកម្ពុជា

លេខ ០០៣ ស.ស.រ

# សេចក្ដីសម្រេច

## ស្ដីពី

## លក្ខខណ្ឌចុះបញ្ជីនិងការកំណត់ប្រាក់ភាគទាន

## នៃគណៈស្ថាបត្យករកម្ពុជា

### ប្រធានក្រុមប្រឹក្សាគណៈស្ថាបត្យករកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១១/១១២៤ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១១ ស្ដីពីការបង្កើតគណៈស្ថាបត្យករកម្ពុជា
- បានឃើញអនុក្រឹត្យលេខ១១១អនក្រ.បក ចុះថ្ងៃទី០១ ខែ សីហា ឆ្នាំ ២០១២ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈស្ថាបត្យករកម្ពុជា
- បានឃើញប្រកាសលេខ១៥៦ប្រក.គសក ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១២ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះផ្នែកនៃអគ្គលេខាធិការដ្ឋាននៃគណៈស្ថាបត្យករកម្ពុជា
- បានទទួលការឯកភាពពីក្រុមប្រឹក្សាគណៈស្ថាបត្យករកម្ពុជាក្នុងកិច្ចប្រជុំលើកទី១ នាថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ២០១៣
- យោងតាមតម្រូវការចាំបាច់របស់គណៈស្ថាបត្យករកម្ពុជា

### សម្រេច

**ប្រការ ១.-**

ជនគ្រប់រូបដែលសុំចុះឈ្មោះក្នុងបញ្ជីគណៈស្ថាបត្យករកម្ពុជា(គ.ស.ក.)ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- បានបញ្ចប់ការសិក្សាជំនាញស្ថាបត្យកម្មឬជំនាញប្រហាក់ប្រហែលដោយជោគជ័យតាមគ្រឹះស្ថានឧត្តមសិក្សានានានៅព្រះរាជាណាចក្រកម្ពុជា ឬនៅបរទេសហើយមានការទទួលស្គាល់សញ្ញាបត្រស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា
- គ្មានការហាមឃាត់ពីការប្រកបវិជ្ជាជីវៈស្ថាបត្យកម្មដោយតុលាការ
- បំពេញបែបបទសុំចុះឈ្មោះក្នុងបញ្ជីតាមទម្រង់ពាក្យសុំចុះបញ្ជីគណៈស្ថាបត្យករកម្ពុជា(គ.ស.ក.) ។

**ប្រការ ២.-**

ជនគ្រប់រូបដែលបានបំពេញលក្ខខណ្ឌដូចប្រការ១ ត្រូវទទួលបានឋានៈជាស្ថាបត្យករចុះបញ្ជី។

**ប្រការ ៣.-**

ស្ថាបត្យករចុះបញ្ជីដែលអាចក្លាយជាស្ថាបត្យករគ.ស.ក. ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម ៖

- មានបទពិសោធការងារក្នុងមុខជំនាញយ៉ាងតិចៈ
  - ថ្នាក់បណ្ឌិត ចំនួន ០១ឆ្នាំ
  - ថ្នាក់អនុបណ្ឌិត ចំនួន ០២ឆ្នាំ
  - ថ្នាក់ស្ថាបត្យករ ឬបរិញ្ញាបត្រស្ថាបត្យកម្ម ឬបរិញ្ញាបត្រប្រហាក់ប្រហែល ចំនួន ០៣ឆ្នាំ
- ឆ្លងកាត់ការវាយតម្លៃលើសមត្ថភាព និងបទពិសោធការងារវិជ្ជាជីវៈតាមរយៈរបាយការណ៍ និងការធ្វើតេស្តដោយសរសេរនិងសំណួរផ្ទាល់មាត់។

**ប្រការ ៤.-**

ស្ថាបត្យករចុះបញ្ជីដែលបានឆ្លងកាត់ដោយជោគជ័យនូវការវាយតម្លៃដូចប្រការ៣ខាងលើត្រូវទទួលឋានៈជាស្ថាបត្យករ គ.ស.ក. ។

ប្រការ ៥.-

ជនបរទេសដែលមានបំណង ឬកំពុងប្រកបវិជ្ជាជីវៈស្ថាបត្យកម្មនៅព្រះរាជាណាចក្រកម្ពុជា ត្រូវបំពេញលក្ខខណ្ឌដូចមានចែងក្នុងប្រការ១ខាងលើ និងទទួលបានការអនុញ្ញាតពីគណៈកម្មការត្រួតពិនិត្យ និងវាយតម្លៃគុណវុឌ្ឍិវិជ្ជាជីវៈស្ថាបត្យកម្ម។

ប្រការ ៦.-

ជនគ្រប់រូប នៅពេលសុំចុះឈ្មោះជាស្ថាបត្យករចុះបញ្ជី ត្រូវបង់ប្រាក់ភាគទានសិទ្ធិចុះឈ្មោះជាសមាជិក គ.ស.ក. ចំនួន ៤០.០០០ (សែសិបពាន់) រៀល។

ប្រការ ៧.-

ស្ថាបត្យករចុះបញ្ជី នៅពេលសុំចុះឈ្មោះជាស្ថាបត្យករគ.ស.ក. ត្រូវបង់ប្រាក់ភាគទានសិទ្ធិចុះឈ្មោះ ចំនួន ២០០.០០០ (ពីររយពាន់) រៀល។

ប្រការ ៨.-

ស្ថាបត្យករគ.ស.ក. នៅពេលសុំចុះឈ្មោះជាស្ថាបត្យករអាស៊ានត្រូវបង់ប្រាក់ភាគទានសិទ្ធិចុះឈ្មោះ ចំនួន ៦០០.០០០ (ប្រាំមួយរយពាន់) រៀល។

ប្រការ ៩.-

ស្ថាបត្យករបរទេស នៅពេលសុំចុះឈ្មោះក្នុងបញ្ជី គ.ស.ក. ដើម្បីប្រកបវិជ្ជាជីវៈស្ថាបត្យកម្ម ត្រូវបង់ប្រាក់ភាគទានសិទ្ធិចុះឈ្មោះចំនួន១.៦០០.០០០ (មួយលានប្រាំមួយរយពាន់)រៀល។

ប្រការ ១០.-

នៅពេលបានចូលជាសមាជិកគ.ស.ក សមាជិកម្នាក់ៗមានកាតព្វកិច្ចបង់ប្រាក់ភាគទាន ប្រចាំឆ្នាំជូន គ.ស.ក. ដូចមានចែងខាងក្រោម៖

- ស្ថាបត្យករចុះបញ្ជី ចំនួន ៨០.០០០ (ប៉ែតសិបពាន់) រៀល
- ស្ថាបត្យករ គ.ស.ក. ចំនួន ២០០.០០០ (ពីររយពាន់) រៀល
- ស្ថាបត្យករ អាស៊ាន ចំនួន ៤០០.០០០ (បួនរយពាន់) រៀល
- ស្ថាបត្យករបរទេសចុះបញ្ជី ចំនួន ១.០០០.០០០ (មួយលាន) រៀល

ប្រាក់ភាគទានទាំងនេះត្រូវបានលើកលែងចំពោះសមាជិកគ.ស.ក. ដែលស្ថិតក្នុងភាពមិនប្រកបវិជ្ជាជីវៈ តែត្រូវមានការឯកភាពជាលាយលក្ខណ៍អក្សរពីប្រធានក្រុមប្រឹក្សាគ.ស.ក.។

**ប្រការ ១១.-**

នៅពេលចូលជាសមាជិកគ.ស.ក. សមាជិកម្នាក់ៗមានកាតព្វកិច្ចធ្វើរបាយការណ៍រៀងរាល់០២(ពីរ)ឆ្នាំម្តង អំពីសកម្មភាពការងារបានអនុវត្ត មកអគ្គលេខាធិការដ្ឋានគ.ស.ក. ដើម្បីពិនិត្យតាមដាននិងវាយតម្លៃលើសមាជិកម្នាក់ៗ ។

**ប្រការ ១២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ ១៣.-**

សេចក្តីសម្រេចនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែ ឧសភា ឆ្នាំ ២០១៣

**ប្រធានក្រុមប្រឹក្សាគណៈស្ថាបត្យករកម្ពុជា**

**អ៊ឹម ឈុនលឹម**

<u>កន្លែងទទួល</u> :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- អគ្គលេខាធិការដ្ឋានគ.ស.ក.
- ឯកសារ-កាលប្បវត្តិ